# រឿង ភ្នំប្រុស ភ្នំស្រី

គូរដោយៈ គឹម សុគន្ធ



# ភ្នំប្រុស ភ្នំស្រី

រៀបរៀងដោយអ្នកស្រី ឱម ធិរិទ្ធ

គូររូបដោយលោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០០២

# រឿង ភ្នំប្រុស ភ្នំស្រី





បើយើងធ្វើដំណើរចេញពីក្រុងភ្នំពេញទៅខេត្តកំពង់ចាម តាមផ្លូវជាតិលេខ ៧ ទៅដល់គោលគីឡូម៉ែត្រទី១១៦ ហើយចោលភ្នែកទៅទិសឦសានដែលនៅខាងឆ្វេងដៃ យើងឃើញភ្នំពីរនៅទន្ទឹមគ្នា ។ ភ្នំមួយខ្ពស់នៅទិសខាងកើតគឺ ភ្នំស្រី ។ ភ្នំមួយទាបនៅទិសខាងលិច គឺភ្នំប្រុស ។





ប្រវត្តិនៃភ្នំទាំងពីរទាក់ទងនឹងរឿងព្រេងមួយ ដែលតំណាលថា កាលពីព្រេងនាយ មានស្ដេចស្រីមួយអង្គព្រះនាម "ស្រីអយុធ្យា" សោយរាជ្យនៅនគរខ្មែរ ។





ដោយព្រះនាងជាស្តេចសោយរាជ្យ ទើបមិនមានបុរសណាហ៊ានចូលដណ្តឹង យកធ្វើជាភរិយាឡើយ ។ ម្ល៉ោះហើយ ព្រះនាងរកដណ្តឹងបុរសដ៏មានរូបឆោមជាទីគាប់ព្រះទ័យមកធ្វើជាព្រះស្វាមី ។

ហេតុដូចនោះ ទើបស្រីៗ ដែលនៅក្រោមបង្គាប់ព្រះនាងក៏ដណ្តឹងប្រុសធ្វើជាស្វាមីដែរ ។





ក្នុងរជ្ជកាលនោះ គួរអោយអាណិតស្រីៗ ខ្លះ ដែលមានរូបសម្ផស្សអន់ ទៅដណ្ដឹងប្រុស ប្រុសគេប្រកែកមិនយក ។ គេយកតែស្រីណាដែលមានរូបល្អធ្វើជាភរិយា ។ ប្រពៃណីនោះ ប្រព្រឹត្តទៅអស់មួយរាជ្យស្ដេចស្រីនេះ ។





លុះដល់រាជ្យស្តេចក្រោយ ពួកស្រីៗជំនុំគ្នាថា "ឥលូវនេះ ដូចជាមិនសមសោះ ខ្លួនយើងជាស្រី ហើយដើរដណ្តឹងប្រុសៗ ធ្វើជាប្តី ។ បើដូចនោះ យើងគិតនាំគ្នាបបួលប្រុសៗ ភ្នាល់លើកដីចាក់ពូន ជាភ្នំ គឺប្រុសៗធ្វើជាភ្នំមួយ ឯស្រីៗក៏ធ្វើជាភ្នំមួយ ដែរ។ បើប្រុសៗចាញ់ ត្រូវអោយប្រុសចូលដណ្តឹង យើងវិញ" ។





ជំនុំគ្នាដូចនោះហើយ ពួកស្រីៗ ក៏ទៅបបួលពួកប្រុសៗធ្វើភ្នំ ដោយចុះខសន្យាភ្នាល់គ្នា ។ ពួកគេបានចាត់អ្នកដើរកេណ្ឌមនុស្សរៀងៗ ខ្លួនអោយបានច្រើន ។ ខាងប្រុសកេណ្ឌប្រុសៗ ឯខាងស្រីកេណ្ឌស្រីៗ ។





លុះកេណ្ឌបានច្រើនគ្រប់ចំនួនហើយ ពួកគេក៏កំណត់លក្ខណ្ឌគ្នាថា "យើងត្រូវជញ្ជូនដី ដរាបដល់ផ្កាយព្រឹករះទើបឈប់ទាំងអស់គ្នា បើផ្កាយព្រឹកមិនទាន់រះ មិនត្រូវឈប់ទេ" ។ ព្រមព្រៀងគ្នាហើយ ពួកគេក៏នាំគ្នាជញ្ជូនដី រែក ទូលតាមសមត្ថភាពរៀងៗ ខ្លួន ។





លុះដល់ពេលយប់ ពួកស្រីៗជញ្ជូនដីអស់វេលាបីបួនម៉ោងប៉ុននោះ ក៏នាំគ្នាបង្គួតគោមតូចមួយយ៉ាងខ្ពស់ នៅជ្រុងឦសានភ្នំ ។



ពួកប្រុសៗ ក្រឡេកមើលទៅឃើញគោមដែលខាងស្រីបង្ហូតនោះ គិតស្មានថាជាផ្កាយព្រឹករះ ក៏នាំគ្នាឈប់ធ្វើការ ហើយនិទ្រាលង់លក់អស់ទៅ ។ ឯពួកស្រីៗ នាំគ្នាប្រឹងជញ្ជូនដីផរាបដល់ផ្កាយព្រឹករះមែនទែន ទើបនាំគ្នាឈប់ ។





ដល់មាន់រងាវកីត ប្រុសៗ ភ្ញាក់ឡើងឃើញផ្កាយព្រឹករះក៏លាន់មាត់ថា "យើងទាំងអស់គ្នាខុសហើយ ផ្កាយព្រឹកមែនទែនទើបតែរះសោះ" ។ រួចហើយគេនាំគ្នាក្រឡេកមើលទៅឃើញភ្នំស្រីមានទំហំធំ ខ្ពស់ជាងភ្នំរបស់ខ្លួន ក៏មានសេចក្ដីអៀនអន់ក្នុងចិត្ត ព្រោះចាញ់កលស្រី ៗ ។







តាំងពីពេលនោះមក ប្រុសៗក៏ដណ្តឹងស្រីៗធ្វើ
ជាភរិយាដរាបដល់សព្វថ្ងៃនេះ ៕

៚ ចប់ ៚



